F2

# ព្រឹត្តិបត្រស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រចាំត្រីមាសទី១ ឆ្នាំ២០២១

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
ក្រុមការងារសម្របសម្រួល ការទូតសេដ្ឋកិច្ច

**សេដ្ឋកិច្ចសកលក្នុងឆ្នាំ២០២១** ត្រូវបានប៉ាន់ស្មានថាកើនឡើងក្នុងអត្រា **៦%** ដោយសារកញ្ចប់ថវិកាស្តារសេដ្ឋកិច្ចនៅ ក្នុងប្រទេសធំៗ ការបង្កើនល្បឿនចាក់វ៉ាក់សាំងក្នុងត្រីមាសទី២ ឆ្នាំ២០២១ ការបន្សាំខ្លួនទៅនឹងសកម្មភាពសេដ្ឋកិច្ចនៅក្នុងប្រក្រតីភាពគន្លងថ្មី (New Normal) និងការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ចនៅក្នុងតំបន់នាចុងឆ្នាំ២០២០។ ក្នុងត្រីមាសទី១ ឆ្នាំ២០២១នេះ យើងឃើញមានការធ្លាក់ចុះនៃសកម្មភាពសេដ្ឋកិច្ចក្នុងវិស័យទេសចរណ៍ សំណង់ វិនិយោគ និងការនាំ ចេញសម្លៀកបំពាក់។ យ៉ាងណាមិញ ផលិតផលនាំចេញផ្សេងទៀតដូចជា កង់ គ្រឿងបន្លាស់អេឡិចត្រូនិក ផលិតផលឈើ និងផលិតផលកសិកម្ម បាននិងកំពុងរក្សាកំណើនល្អ ។

## ស្ថានភាពហិរញ្ញវត្ថុសាធារណៈ

**ចំណូលសរុប**
៥,១
ទ្រីលានរៀល

២៥,៧%
នៃច្បាប់ថវិកាឆ្នាំ២០២១
-៧,៥% ↓

ចំណូលចរន្ត
៥,១
ទ្រីលានរៀល
-៧,៥% ↓

ដោយសារការថមថយសកម្មភាពសេដ្ឋកិច្ច និងការបន្ធូរបន្ថយកាតព្វកិច្ចពន្ធ និងមិនមែនពន្ធ

**ចំណាយសរុប**
៥,៨
ទ្រីលានរៀល

១៩,៦%
នៃច្បាប់ថវិកាឆ្នាំ២០២១
៤,២% ↑

ចំណាយចរន្ត
៣,៥
ទ្រីលានរៀល
-១២,៧% ↓

ការអនុវត្តថវិកាមានអតិរេកចំនួន
១,៦
ទ្រីលានរៀល

*ប្រៀបធៀបទៅនឹងត្រីមាសទី១ ឆ្នាំ២០២០

## ស្ថានភាពរូបិយវត្ថុ

រូបិយវត្ថុទូទៅ
១៤៣,៤
ទ្រីលានរៀល
២០,៣% ↑

ទុនបម្រុងរូបិយបណ្ណបរទេសដុល
២០,៣
ប៊ីលានរៀល
១០% ↑

ឥណទានដែលផ្តល់ដោយធនាគារពាណិជ្ជ
១៣៨,៤
ទ្រីលានរៀល
២២,៨% ↑

## ពាណិជ្ជកម្ម

ការនាំចូល
៧,៥
ប៊ីលានរៀល
៤៨,៧% ↑
ដោយសារកំណើននាំចូលវាយនភណ្ឌ និងសម្លៀកបំពាក់ បរិក្ខារសំណង់ ថ្នាំពេទ្យ និងគ្រឿងឧបភោគបរិភោគ។

ការនាំចេញ
៣,៨
ប៊ីលានរៀល
៧% ↑
ដោយសារកំណើននាំចេញនៃផលិតផលមិនមែនកាត់ដេរ ដូចជា កង់ គ្រឿងបង្គុំអេឡិចត្រូនិច និងផលិតផលកសិកម្ម។

## វិនិយោគ

គម្រោងវិនិយោគក្រៅតំបន់សេដ្ឋកិច្ចពិសេស
អនុម័តបាន
២៨
គម្រោង
១៧ ↓

ទុនវិនិយោគ
៦៧៩,៦
លានដុល្លារ
-២៥,៨% ↓
ដោយសារការធ្លាក់ចុះនៃគម្រោងសាងសង់ផ្នែកទេសចរណ៍ សណ្ឋាគារ មជ្ឈមណ្ឌលសេវាកម្មសុខាភិបាល និងរោងចក្រកាត់ដេរ។

## ទេសចរណ៍

ភ្ញៀវទេសចរអន្តរជាតិសរុប
៧០ ៩០១នាក់
-៩៣,៩% ↓
ដោយសារការរឹតត្បិតការធ្វើដំណើរ

## សំណង់

អនុម័តបាន
១ ០៦៦
គម្រោង
៥០គម្រោង ឬ -៤,៥% ↓
ដោយសារការថយចុះនៃគម្រោងសំណង់ផ្នែកសាធារណៈ លំនៅឋាន ពាណិជ្ជកម្ម ទេសចរណ៍ និងសំណង់វិនិយោគ។